**សេចក្ដីព្រាង**

# សុន្ទរកថាបើក

## ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ថ្លែងក្នុងពិធីបើកសន្និបាតបូកសរុបសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥

ថ្ងៃចន្ទ ១០រោច ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៦

ជាបឋម ខ្ញុំសូមគោរពៈ

- ឯកឧត្តម លោកជំទាវគណៈអធិបតី
- ឯកឧត្តម សន្តិបណ្ឌិត រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ
- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ តំណាងក្រសួង ស្ថាប័ន
- ឯកឧត្តមប្រធានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត
- ឯកឧត្តម ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត និង ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត
- ឯកឧត្តមប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន
- លោក លោកស្រីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ
- លោក លោកស្រីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់
- លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ដែលមានវត្តមានដោយផ្ទាល់ និងចូលរួមតាមប្រព័ន្ធអនឡាញ ជាទីគោរព និងជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមជាអធិបតីក្នុងពិធីបើក«**សន្និបាតបូកសរុបសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥**» ជាមួយវត្តមានដ៏ឧត្តុង្គឧត្តមរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានធ្វើដំណើរពីគ្រប់មូលដ្ឋានទូទាំងប្រទេសអញ្ជើញមកចូលរួមដោយផ្ទាល់និងតាមប្រព័ន្ធអនឡាញក្នុងព្រឹត្តិការណ៍ដ៏មានសារៈសំខាន់នេះ។

ជាបឋម ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមក្រសួងមហាផ្ទៃ ខ្ញុំសូមថ្លែងអំណរសាទរ និងកោតសរសើរយ៉ាងស្មោះស្ម័គ្រចំពោះការខិតខំប្រឹងប្រែងបំពេញការងារដោយមិនចេះនឿយហត់របស់

សមាជិក សមាជិកាក្រុមប្រឹក្សា មេឃុំ ចៅសង្កាត់ អាណត្តិទី៥ និងស្មៀនឃុំ សង្កាត់ ព្រមទាំងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ដែលបានបំពេញភារកិច្ចយ៉ាងសកម្មបម្រើជាតិ មាតុភូមិ និងប្រជាជនក្នុងអំឡុងពេលជាង ៤ឆ្នាំកន្លងមកនេះ។ ទន្ទឹមនេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះតំណាងស្ថានទូត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិទាំងអស់ ដែលបានចូលរួមគាំទ្រដល់ការអភិវឌ្ឍប្រទេសកម្ពុជានិងជាដៃគូដ៏ស្មោះត្រង់ជាមួយរាជរដ្ឋាភិបាល ក្នុងការជំរុញនិងគាំទ្រដល់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ចាប់តាំងពីដំណាក់កាលដំបូងរហូតមកដល់បច្ចុប្បន្ននេះ។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសន្និបាតជាទីមេត្រី!

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ ខ្ញុំសូមគូសបញ្ជាក់ជូនអង្គសន្និបាតថា រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧នេះ នៅតែតម្កល់ធន្ទៈមោះមុតក្នុងការបន្តជំរុញនិងពង្រឹងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឬហៅថា «**កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**» ដែលជាកំណែទម្រង់ផ្នែកអភិបាលកិច្ចមានផលប៉ះពាល់ដោយផ្ទាល់ដល់ការលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅតាមមូលដ្ឋាន។ បន្ទាប់ពីការចាប់ផ្តើមនៅឆ្នាំ២០០២ ការកែទម្រង់វិមជ្ឈការនៅរដ្ឋបាលឃុំ សង្កាត់ បានអនុញ្ញាតឱ្យរដ្ឋបាលឃុំ សង្កាត់ ដែលដឹកនាំដោយក្រុមប្រឹក្សាកើតចេញពីការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ បានបំពេញតួនាទីជាតំណាងឱ្យសំឡេងនិងផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនអស់រយៈពេលប្រមាណជាង២៤ឆ្នាំមកហើយ។ ការបោះឆ្នោតដោយផ្ទាល់នៅថ្នាក់ឃុំ សង្កាត់ គឺជាយន្តការដ៏សំខាន់ក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ចាប់ពីថ្នាក់មូលដ្ឋាន ដែលជាការចូលរួមពង្រឹងស្ថិរភាពនយោបាយ ស្ថិរភាពសង្គម និងបង្កើតបរិយាកាសសម្រាប់អភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីចម្រើនជាលំដាប់។ ទន្ទឹមនេះ ការកែទម្រង់វិមជ្ឈការ បានធ្វើឱ្យរដ្ឋបាលឃុំ សង្កាត់នីមួយៗ មានសិទ្ធិអំណាច មុខងារ ធនធាន ការទទួលខុសត្រូវ និងមានគណនេយ្យភាពច្បាស់លាស់ក្នុងការគ្រប់គ្រងចាត់ចែងកិច្ចការនានា ដែលពាក់ព័ន្ធទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាននីមួយៗ និងជាកិច្ចការសកលដែលប្រទេសភាគច្រើនលើសកលលោក បាននិងកំពុងពង្រឹងកែលម្អប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ជាពិសេសពង្រឹងភាពធន់របស់មូលដ្ឋានក្នុងការចូលរួមទប់ស្កាត់ ដោះស្រាយ ឆ្លើយតបប្រកបដោយភាពជាម្ចាស់ចំពោះវិបត្តិ និងបញ្ហាប្រឈមនានានៅមូលដ្ឋាន ដែលបណ្ដាលមកពីការវិវត្តប្រែប្រួលមិនទៀងនៃសភាពការណ៍ក្នុងតំបន់និងសកលលោក រួមទាំងការប្រែប្រួលអាកាសធាតុ សំដៅចូលរួមអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។ ត្រង់ចំណុចនេះ ខ្ញុំសូមរំលឹកឡើងវិញអំពីសង្គ្រាមឈ្លានពានរបស់កងទ័ពថៃមកលើបូរណភាពទឹកដីនិងអធិបតេយ្យជាតិយើង កាលពីឆមាសទី២ ឆ្នាំ២០២៥ កន្លងមកនេះ ដែលបានបង្កឱ្យបាត់បង់អាយុជីវិតនិងរងរបួសជនស៊ីវិល ការខូចខាតផ្ទះសម្បែងជាច្រើនពាន់ខ្នង ខូចខាតហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គមរាប់រយកន្លែង ជាពិសេសសង្គ្រាមឈ្លានពាននេះបានបង្កើតឱ្យមានវិបត្តិជនភៀសសឹកយ៉ាងគំហុករហូតទៅដល់ជាង**៦៤ម៉ឺននាក់** និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករជិត**៩៣ម៉ឺននាក់** មកពីប្រទេសថៃ។ ប្រឆាំងនឹងការឈ្លានពាននេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមប្រមុខដឹកនាំរបស់ **សម្ដេចតេជោប្រធានព្រឹទ្ធសភា និងសម្ដេចធិបតីនាយករដ្ឋមន្ត្រី** បានបញ្ជាដឹកនាំកងយោធពលខេមរភូមិន្ទនិងកងកម្លាំងនគរបាលជាតិ ប្រកៀកស្មាតស៊ូប្រយុទ្ធយ៉ាងអង់អាចក្លាហានបំផុត

ដើម្បីការពារបូរណភាពទឹកដីកម្ពុជា។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានចាត់វិធានការប្រកបដោយប្រសិទ្ធភាពក្នុងការដោះស្រាយវិបត្តិមនុស្សធម៌ពីសង្គ្រាមឈ្លានពានរបស់កងទ័ពថៃ តាមរយៈការរៀបចំជាស្រេចនូវមណ្ឌលសុវត្ថិភាពសម្រាប់ជនភៀសសឹក ការវាយតម្លៃការខូចខាតនិងការដោះស្រាយផលប៉ះពាល់ជូនប្រជាពលរដ្ឋ ការសាងសង់ផ្ទះបណ្តោះអាសន្នសម្រាប់ជនភៀសសឹករាប់ពាន់គ្រួសារ ការផ្សព្វផ្សាយនិងជំរុញឱកាសការងារជូនពលករ និងការអន្តរាគមន៍តាមរយៈកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ប្រចាំខែដើម្បីរក្សាលំនឹងជីវភាពជនភៀសសឹកបានទាន់ពេលវេលា ដែលកត្តាទាំងនេះសុទ្ធតែមានចំណែកចូលរួមយ៉ាងសកម្មមិនអាចខ្វះបាននិងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីរដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេសរដ្ឋបាលឃុំ សង្កាត់។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសន្និបាតជាទីមេត្រី!

ផ្អែកលើសមិទ្ធផលជាវិជ្ជមាននៃការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានពង្រីកវិសាលភាពនៃការកែទម្រង់នេះ ទៅគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត តាមរយៈការរៀបចំមានជាអាទិ៍ ១).ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ នៅឆ្នាំ២០០៥ ២).ការរៀបចំច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅឆ្នាំ២០០៨ និង៣).ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅឆ្នាំ២០០៩ ព្រមទាំងបានដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

តាមរយៈការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងរយៈពេលជាង ២ទសវត្សរ៍កន្លងមកនេះ ទន្ទឹមនឹងការកសាងបាននូវក្របខ័ណ្ឌគតិយុត្ត ការរៀបចំរចនាសម្ព័ន្ធស្ថាប័ន ក៏ដូចជាការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិទាំង**៣កម្រិត**(ឃុំ-សង្កាត់, ក្រុង-ស្រុក-ខណ្ឌ, រាជធានី-ខេត្ត) ខ្ញុំសូមធ្វើការកត់សម្គាល់នូវសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

**ទី១-ការពង្រឹងនិងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនិងអភិបាលកិច្ចនៅមូលដ្ឋាន៖**

ការធ្វើវិមជ្ឈការ ពិតជាបានចូលរួមចំណែកសំខាន់ដល់ការពង្រឹងនិងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការពង្រឹងស្ថិរភាពនយោបាយនិងអភិបាលកិច្ច ព្រមទាំងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដោយមានការចូលរួមពីប្រជាពលរដ្ឋ ការកសាងឡើងវិញនូវមូលធនសង្គមនិងមូលធននយោបាយដែលជាគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍប្រទេសជាតិ ប្រកបដោយគុណភាព ប្រសិទ្ធភាព និរន្តរភាព បរិយាបន្ននិងសមធម៌។ ក្នុងរយៈពេលកន្លងមកនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ និងតួអង្គពាក់ព័ន្ធនៅតាមមូលដ្ឋានរួមទាំងអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងប្រជាពលរដ្ឋ បានប្រឹងប្រែងរួមគ្នាបង្កើតវប្បធម៌ នៃការចូលរួមលើកកម្ពស់ភាពម្ចាស់ការ តម្លាភាព គណនេយ្យភាព ការឆ្លើយតប បរិយាបន្ន និងសមធម៌ ដែលជាគោលការណ៍គន្លឹះនៃអភិបាលកិច្ចល្អ និងជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ដែល“**ផ្តោតលើការពង្រឹងអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើបប្រកបដោយសមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និងស្អាតស្អំ ដើម្បីធានានិរន្តរភាព តួនាទី និងដំណើរការរដ្ឋបាលសាធារណៈ ដោយតម្កល់ផលប្រយោជន៍**

**ប្រជាជនជាធំ ព្រមជាមួយការកសាងជាតិ និងការពង្រឹងនីតិរដ្ឋ សំដៅដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និងចីរភាព»** ដែលជាសមិទ្ធផលគន្លឹះពាក់ព័ន្ធនឹងការពង្រឹងនិងពង្រីកដំណើរការលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ការពង្រឹងស្ថិរភាពនយោបាយ, ការចូលរួមថែរក្សាការពារ សុខសន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និងនិរន្តរភាព។

**ទី២-ការគ្រប់គ្រងនិងការប្រើប្រាស់ហិរញ្ញវត្ថុ៖**

រាជរដ្ឋាភិបាល បានសម្រេចផ្តល់ប្រភពធនធានហិរញ្ញវត្ថុ តាមរយៈការបង្កើតនូវមូលនិធិឃុំ សង្កាត់ ដើម្បីឱ្យរដ្ឋបាលឃុំ សង្កាត់ មានលទ្ធភាពនិងគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅក្នុងការអភិវឌ្ឍ និង លើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ នៅឆ្នាំ២០០២ មូលនិធិមានទំហំត្រឹមតែ ប្រមាណ **៨លានដុល្លារអាម៉េរិក** បើគិតជាមធ្យមភាគឃុំ សង្កាត់នីមួយៗទទួលបានប្រហែល **៥.០០០ ដុល្លារអាមេរិក**ប៉ុណ្ណោះ នឹងមានការកើនឡើងជាបន្តបន្ទាប់រហូតដល់ឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជា បាន សម្រេចផ្តល់មូលនិធិ**១%** នៃចំណូលចរន្តថវិកាថ្នាក់ជាតិ និងពន្ធចែករំលែកចំណូលសារពើពន្ធរាជធានី ខេត្ត **៦%** បន្ថែមលើមូលនិធិឃុំ សង្កាត់ សម្រាប់ការចំណាយលើការអភិវឌ្ឍមូលដ្ឋានដល់ឃុំ សង្កាត់ទូទាំង ប្រទេស( លើកលែងសង្កាត់ក្នុងរាជធានីភ្នំពេញ ) ដែលគិតត្រឹមឆ្នាំ២០២៦នេះ មូលនិធិឃុំ សង្កាត់ បាន កើនដល់រហូតដល់ប្រមាណ **៣៣៣លានដុល្លារអាម៉េរិក** គិតជាមធ្យមភាគឃុំ សង្កាត់នីមួយៗទទួលបាន ប្រហែល **២០០.០០០ដុល្លាអាម៉េរិក** កើនឡើងជាង **៤១ដង** បើធៀបនឹងមធ្យមភាគឃុំ សង្កាត់ទទួលបាន កាលពីឆ្នាំ២០០២ សម្រាប់ការចំណាយលើការអភិវឌ្ឍន៍មូលដ្ឋានដល់ឃុំ សង្កាត់ទូទាំងប្រទេស នេះមិន ទាន់គិតបញ្ចូលមូលនិធិភាតរភាព ដែលមានប្រហែល **១២.០០០ដុល្លាអាម៉េរិក/ឃុំ សង្កាត់** នៅឆ្នាំ២០២៧ ខាងមុខនេះ។

**ទី៣-ការលើកកម្ពស់ការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន៖**

គោលបំណងចម្បងនៃការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺការលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការបែងចែកផលប្រយោជន៍នៃការអភិវឌ្ឍប្រកបដោយបរិយាបន្ន ចីរភាព និងសមធម៌ ។ ដើម្បីសម្រេចបាននូវគោលបំណងដ៏ពិសិដ្ឋនេះ ការកែទម្រង់បានផ្តោតលើការរៀបចំ ឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរមុខងារ ធនធាន និងការទទួល ខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណង «**បង្វិតសេវាឱ្យទៅកៀកជិត ប្រជាពលរដ្ឋ**» សំដៅ បង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋទទួលបានសេវាឆាប់រហ័ស តម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាព នៅតាមមូលដ្ឋាន។

ផ្តើមចេញពីការប្តេជ្ញាចិត្តខ្ពស់និងប្រកាន់ខ្ជាប់នូវវិធីសាស្ត្រអនុវត្តប្រកបដោយភាពបត់បែន ទន់ភ្លន់ តែម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាល ដោយមានការចូលរួមគាំទ្រពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសង្គម ស៊ីវិល វិស័យឯកជន និងប្រជាពលរដ្ឋ ក្នុងការអនុវត្តការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងរយៈពេល ជាង២ទសវត្សរ៍កន្លងមកនេះ បានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ក្លាយជាស្ថាប័នសាធារណៈ

មានរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ច រួមមាន៖ ប្រព័ន្ធកសាងផែនការ, ប្រព័ន្ធគ្រប់គ្រងបុគ្គលិក, ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ, នីតិវិធីបំពេញការងារនិងនីតិវិធីនៃការផ្តល់សេវា ព្រមទាំងមានមុខងារ ធនធាន ការទទួលខុសត្រូវកាន់តែច្បាស់លាស់ និងមានភាពធន់, ភាពម្ចាស់ការក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ដោះស្រាយបញ្ហាលំបាកនៅតាមមូលដ្ឋានបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, បរិយាបន្ន, ចីរភាព និងសមធម៌។

ផ្អែកលើមូលនិធិខាងលើ រដ្ឋបាលឃុំ សង្កាត់ បានខិតខំយកចិត្តទុកដាក់រៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគនានា តាមរយៈការរៀបចំនិងអនុវត្តគម្រោងអភិវឌ្ឍន៍នៅមូលដ្ឋាន សរុបប្រមាណជាង **២.២០០គម្រោង**ក្នុងមួយឆ្នាំៗ ជាពិសេសគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តរួមមាន៖ ការសាងសង់ឬជួសជុលផ្លូវបេតុង ផ្លូវលំ ស្ពានខ្នាតតូច សំណង់សិល្បការ្យ សាលារៀន មណ្ឌលសុខភាព ប្រព័ន្ធធារាសាស្ត្រខ្នាតតូច។ល។ បន្ថែមលើពីនេះ នៅមានគម្រោងឬសកម្មភាពសេវាសង្គម និងអនាម័យបរិស្ថានជាច្រើនទៀតក៏ត្រូវបានអនុវត្តក្នុងមួយឆ្នាំៗផងដែរ។ គម្រោងទាំងនេះពិតជាបានរួមចំណែកគួរឱ្យកត់សម្គាល់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅមូលដ្ឋាន និងជួយលើកកម្ពស់ជីវភាពរស់នៅ កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### **ទី៤**-ការចូលរួមកាត់បន្ថយភាពក្រីក្រដោយផ្ទាល់នៅតាមមូលដ្ឋាន៖

ភាពក្រីក្រ គឺជាបញ្ហាសង្គមដ៏ធំមួយ ដែលរាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់កាត់បន្ថយជាបន្តបន្ទាប់។ នៅក្នុងទិសដៅកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាល បាននិងកំពុងដាក់ចេញនូវវិធានការចម្រុះដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចលើគ្រប់វិស័យ និងការអនុវត្តគោលនយោបាយជាតិគាំពារសង្គម។ ជាក់ស្តែងក្នុងរយៈពេលជាង២៥ឆ្នាំកន្លងមកនេះ អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយចាប់ពីអត្រាជាង **៥0%** នៅដើមទសវត្សរ៍ ឆ្នាំ២០០០ មកនៅត្រឹមជាង**១0%** នៅមុនវិបត្តិជំងឺកូវីដ-១៩។

### **ទី៥**-ការសម្រុះសម្រួលនិងដោះស្រាយវិវាទមូលដ្ឋាន៖

រដ្ឋបាលឃុំ សង្កាត់ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រុះសម្រួលនិងដោះស្រាយវិវាទនៅមូលដ្ឋានដោយសន្តិវិធី ដោយមិនចាំបាច់ឡើងទៅតុលាការដែលបានជួយសន្សំ សំចៃពេលវេលានិងការចំណាយរបស់ប្រជាពលរដ្ឋ ព្រមទាំងបានកាត់បន្ថយបន្ទុករបស់ស្ថាប័នតុលាការ និងសំខាន់ជាងនេះទៅទៀត បានរួមចំណែករក្សានូវសាមគ្គីភាព និងសង្គមសុខដុមរមនានៅមូលដ្ឋាន។

### **ទី៦**-ការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព៖

លទ្ធផលប្រឡងប្រណាំងភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៥ បានបង្ហាញថា ឃុំ សង្កាត់ចំនួន **១.២៤៣** ទទួលបានចំណាត់ថ្នាក់លេខ**១**, ឃុំ សង្កាត់ចំនួន **៣៦៤** ទទួលបានចំណាត់ថ្នាក់លេខ**២** និងឃុំ សង្កាត់ចំនួន **៤១** ទទួលបានចំណាត់ថ្នាក់លេខ**៣**។ លទ្ធផលនេះ បានបង្ហាញឱ្យឃើញថា រដ្ឋបាលឃុំ សង្កាត់ភាគច្រើនលើសលប់បាន ចូលរួមយ៉ាងសកម្ម ក្នុងការធានាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមនៅមូលដ្ឋាន ដែលជាលក្ខខណ្ឌចាំបាច់មួយសម្រាប់ការអភិវឌ្ឍ និងការវិនិយោគ។

**ទី៧**-ក្រៅពីសមិទ្ធផលសម្រេចបានជាច្រើនដូចបានរៀបរាប់ខាងលើ រដ្ឋបាលឃុំ សង្កាត់ក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តនូវគោលនយោបាយជាតិគាំពារសង្គម តាមរយៈកម្មវិធីជាតិជំនួយសង្គមពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងការជួយឧបត្ថម្ភដល់ជនងាយរងគ្រោះផ្សេងៗ ដើម្បីជួយសម្រាលទុក្ខលំបាកដល់ប្រជាពលរដ្ឋដែលកំពុងតែប្រឈមបញ្ហាខ្វះខាត។ ទន្ទឹមនេះ ក៏នៅមានកិច្ចការផ្សេងៗជាច្រើនទៀតដូចជា៖ ការចុះឈ្មោះ/ចែកប័ណ្ណព័ត៌មានបោះឆ្នោត ការអប់រំមត្តេយ្យសហគមន៍ មណ្ឌលសុខភាព និងកិច្ចការផ្សេងៗទៀត ដែលរដ្ឋបាលឃុំ សង្កាត់ត្រូវបានស្នើសុំកិច្ចសហការពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីធ្វើជាភ្នាក់ងារក្នុងការអនុវត្តមុខងារឬកម្មវិធីឬគម្រោងផ្សេងៗ។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសន្និបាតជាទីមេត្រី!

ទន្ទឹមនឹងសមិទ្ធផលការងារសម្រេចបានយ៉ាងធំធេង ដូចដែលខ្ញុំបានលើកឡើងខាងលើ វាគឺជាមោទនភាពរួមរបស់យើងទាំងអស់គ្នា។ ប៉ុន្តែការអនុវត្តជាក់ស្តែង នៅតាមមូលដ្ឋានក៏នៅមានបញ្ហាប្រឈម និងចំណុចខ្វះខាតជាច្រើនផងដែរ ដែលអង្គសន្និបាត ចាំបាច់ត្រូវលើកយកមកពិនិត្យ ពិចារណា និងពិភាក្សារួមគ្នាឱ្យបានស៊ីជម្រៅ រួមមាន៖

**ទី១-គុណភាពនិងសមត្ថភាពមិនទាន់ស្មើគ្នារវាងឃុំ សង្កាត់៖** ការវាយតម្លៃបានបង្ហាញថា សមិទ្ធផល និងគុណភាពការងារនៅមិនទាន់មានកម្រិតស្មើគ្នារវាងឃុំ សង្កាត់ទាំងអស់នៅឡើយទេ។ ភាពខុសគ្នានេះទាក់ទងនឹងស្ថានភាពទីតាំងភូមិសាស្ត្រ ប្រជាសាស្ត្រ ធនធានហិរញ្ញវត្ថុ សមត្ថភាពធនធានមនុស្សនិងកម្រិតនៃការគាំទ្រពីថ្នាក់ជាតិ និងភាគីពាក់ព័ន្ធ។ ជាពិសេសចំពោះឃុំ សង្កាត់ដែលនៅដាច់ស្រយាល និងមានលក្ខខណ្ឌលំបាកទាំងហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម។ល។

**ទី២-ភាពយឺតយ៉ាវនៃការផ្ទេរធនធាន៖** ការផ្ទេរធនធានពីថវិការដ្ឋក្នុងឆ្នាំនីមួយៗនៅមានភាពយឺតយ៉ាវ ហើយរដ្ឋបាលឃុំ សង្កាត់ខ្លះត្រូវរង់ចាំរហូតដល់ការវិភាជថវិកាត្រីមាសទី៣ ទើបមានធនធានគ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងបានពេញលេញ។ កត្តានេះ បណ្តាលឱ្យការរៀបចំនិងអនុវត្តគម្រោងមានការយឺតយ៉ាវ ហើយប្រមូលផ្តុំការអនុវត្តនៅចុងឆ្នាំ ដែលនាំឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព និងគុណភាពការងារ។ ខ្ញុំសូមផ្តាំផ្ញើថា ការពង្រឹងប្រសិទ្ធភាពថវិកា មិនត្រូវផ្តោតតែលើ «**ការបង្កើនទំហំថវិកា**» ប៉ុណ្ណោះទេ ប៉ុន្តែត្រូវយកចិត្តទុកដាក់លើពេលវេលានៃការផ្ទេរធនធានថវិកា ភាពបត់បែននៃការប្រើប្រាស់សមត្ថភាពគ្រប់គ្រង និងគុណភាពចំណាយផងដែរ។

**ទី៣-ការផ្ទេរមុខងារមិនទាន់ស្របគ្នាជាមួយធនធាន៖** នៅមានករណីខ្លះដែលមុខងារត្រូវបានផ្ទេរមកឃុំ សង្កាត់រួចហើយ ប៉ុន្តែធនធានថវិកា ទ្រព្យសម្បត្តិ បុគ្គលិក និងសិទ្ធិសម្រេចនៅមិនទាន់បានផ្ទេរតាមឱ្យបានគ្រប់គ្រាន់នៅឡើយ កត្តានេះបានបង្កើតជាបន្ទុកបន្ថែមដល់មន្ត្រីមូលដ្ឋាន។

**ទី៤-សមត្ថភាពបច្ចេកទេសក្នុងការរៀបចំនិងអនុវត្តគម្រោង៖** គុណភាពនៃការរៀបចំផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគ មិនអាស្រ័យតែលើទំហំថវិកានោះទេ ប៉ុន្តែអាស្រ័យលើគុណភាពនៃការសិក្សាសមិទ្ធិលទ្ធភាពគម្រោងនីមួយៗ ការរចនាប្លង់បច្ចេកទេស ការគ្រប់គ្រងកិច្ចលទ្ធកម្ម កិច្ចសន្យា និងការ

ត្រួតពិនិត្យគុណភាពសំណង់ផងដែរ។

**ទី៥-បន្ទុកការងាររបស់ស្មៀននិងបុគ្គលិកឃុំ សង្កាត់៖** ការពង្រីកតួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់ បានធ្វើឱ្យបន្ទុកការងាររបស់ស្មៀន និងបុគ្គលិកកើនឡើងគួរឱ្យកត់សម្គាល់ ដែលទាមទារឱ្យមានការពិនិត្យមើលឡើងវិញទៅលើរចនាសម្ព័ន្ធ បុគ្គលិក និងលក្ខខណ្ឌការងារ។ល។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសន្និបាតជាទីមេត្រី!

សន្និបាតនាពេលនេះ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់របស់ព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំឡើងក្នុងគោលបំណងដើម្បីប្រមូលផ្តុំនូវគ្រប់ភាគីពាក់ព័ន្ធរួមគ្នាពិនិត្យពិភាក្សានិងវាយតម្លៃលើសមិទ្ធផល បញ្ហាប្រឈម សំណើ សំណូមពរ និងរកដំណោះស្រាយ នៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងអាណត្តិទី៥ ដើម្បីផ្តល់ឱកាសធ្វើការចែករំលែកនូវមេរៀន បទពិសោធល្អៗ និងកំណត់ទិសដៅឱ្យបានច្បាស់លាស់សម្រាប់យកទៅអនុវត្តការងារនៅក្នុងអាណត្តិទី៦នាឆ្នាំ២០២៧ខាងមុខឱ្យកាន់តែមានភាពល្អប្រសើរឡើង។ ការរៀបចំសន្និបាតក្នុងរយៈពេល១ថ្ងៃកន្លះនេះ ពុំបានរៀបចំការពិភាក្សាជាក្រុមនោះទេ គឺសន្និបាតរៀបចំឱ្យមានការធ្វើបទអន្តរាគមន៍ពីក្រសួង ស្ថាប័នានា និងបទបង្ហាញពីការចែករំលែកបទពិសោធក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ ជាមួយនឹងបទបង្ហាញវាយតម្លៃលើការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ពីស្ថាប័នសិក្សាស្រាវជ្រាវ CDRI ដែលជាការវាយតម្លៃផ្ទៃក្រៅ និងឯករាជ្យ។ ជាមួយគ្នានេះ សន្និបាតក៏រៀបចំឱ្យមានការជជែកពិភាក្សារបស់វាគ្មិនមកពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធលើការគាំទ្រដល់ការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ផងដែរ។

ក្នុងន័យនេះ សមិទ្ធផលទាំងអស់ដែលយើងសម្រេចបានក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ គឺជាផលផ្លែនៃ«**នយោបាយឈ្នះ-ឈ្នះ**» ដែលនាំមកនូវសុខសន្តិភាព ឯកភាពជាតិ ឯកភាពទឹកដី និងស្ថិរភាពនយោបាយ ក្រោមការដឹកនាំដ៏ត្រឹមត្រូវនិងឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា** និងដឹកនាំបន្តប្រកបដោយឆន្ទៈមោះមុតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ដូច្នេះ សូមឱ្យយើងទាំងអស់គ្នាបានយល់ដឹង ចងចាំ និងថែរក្សានូវសមិទ្ធផលដ៏ថ្លៃថ្លានេះ។ ចំពោះសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ខ្ញុំសូមថ្លែងអំណរគុណ វាយតម្លៃខ្ពស់ និងកោតសរសើរម្តងទៀត ចំពោះការលះបង់និងការបំពេញតួនាទី ភារកិច្ចយ៉ាងសកម្មក្នុងរយៈពេលមួយអាណត្តិកន្លងមកនេះ។ «**លោក លោកស្រីទាំងអស់ គឺជាអ្នកនៅជួរមុខក្នុងការនាំយកគោលនយោបាយ និងកម្មវិធីនយោបាយនានារបស់រាជរដ្ឋាភិបាល ទៅដល់ដំបូលផ្ទះរបស់ប្រជាពលរដ្ឋ**»។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សន្និបាតរយៈពេលមួយថ្ងៃកន្លះនេះ នឹងក្លាយជាវេទិកាដ៏មានអត្ថប្រយោជន៍សម្រាប់ការចែករំលែកបទពិសោធល្អៗ ការពិភាក្សាដោយបើកចំហ និងការផ្តល់អនុសាសន៍ដ៏មានតម្លៃ ដើម្បីរួមចំណែកលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការឆ្លើយតបរបស់

ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនសម្រាប់អាណត្តិទី៦ ឱ្យកាន់តែច្បាស់លាស់ និងទទួលបានលទ្ធផលជាក់ស្តែង។

ខ្ញុំសូមស្នើឱ្យអង្គសន្និបាតទាំងមូលធ្វើការពិភាក្សាដោយស្មោះត្រង់ ដោយហ៊ានលើកឡើង ទាំងចំណុចខ្លាំង និងចំណុចខ្វះខាត សំណើ សំណូមពរនានា ព្រោះការវិភាគវាយតម្លៃទទួលបានលទ្ធផលល្អ ត្រឹមត្រូវ គឺជាមូលដ្ឋាននៃការសម្រេចចិត្តត្រឹមត្រូវផងដែរ។

ជាទីបញ្ចប់ ខ្ញុំសូមប្រកាសបើក «**សន្និបាតបូកសរុបសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥**» ចាប់ពីពេលនេះតទៅ។

សូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសន្និបាតទាំងមូល ប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងជោគជ័យគ្រប់ភារកិច្ច។

**សូមអរគុណ**!